**EU VAT**

# ការណែនាំអំពីការប្រើប្រាស់លេខ IOSS របស់លោកអ្នក




សហភាពអឺរ៉ុបបានណែនាំអំពីប្រព័ន្ធនាំចូល One-Stop Shop (IOSS) កាលពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2021 ដើម្បីជួយជម្រុញដល់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកអន្តរជាតិ។ IOSS មានភាពងាយស្រួលក្នុងការប្រើប្រាស់ ប៉ុន្តែអ្វីដែលសំខាន់គឺតើបញ្ញើទំនិញរបស់លោកអ្នកបំពេញលក្ខខណ្ឌ្តិកៈមួយចំនួន ហើយឯកសារដឹកជញ្ជូនត្រូវតែបានបំពេញត្រឹមត្រូវដែរឬទេ។

## ការប្រើប្រាស់ IOSS៖ ចំណុចសំខាន់ 6 ដែលត្រូវដឹង

រាល់ពេលដែលលោកអ្នកផ្ញើបញ្ញើទំនិញដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ លោកអ្នកត្រូវផ្ដល់លេខ IOSS របស់លោកអ្នក និងអនុវត្តតាមជំហានទាំងនេះ។

1. សូមធានាថា ការលក់របស់លោកអ្នកត្រូវបានធ្វើឡើងតាមរយៈគេហទំព័ររបស់អ្នក។ ប្រសិនបើវាធ្វើឡើងតាមរយៈទីផ្សារលក់ IOSS ដែលបានចុះបញ្ជី លោកអ្នកត្រូវផ្ដល់លេខ IOSS របស់ទីផ្សារនោះ។ លោកអ្នក មិនអាចប្រើប្រាស់លេខ IOSS ផ្ទាល់ខ្លួនសម្រាប់ការលក់តាមរយៈទីផ្សារលក់បានទេ។

2. សូមបញ្ជាក់ថាបញ្ញើទំនិញរបស់លោកអ្នកផ្ញើទៅឱ្យអ្នកប្រើប្រាស់ផ្ទាល់ (B2C) មិនមែនសម្រាប់អាជីវកម្ម (B2B) ទេ។ IOSS ប្រើប្រាស់បានតែសម្រាប់បញ្ញើទំនិញតាមប្រព័ន្ធអេឡិចត្រូនិក B2C ដែលមិនជាប់ពន្ធលើមុខទំនិញតែប៉ុណ្ណោះ។

3. សូមធានាថា បញ្ញើទំនិញដឹកជញ្ជូនទៅកាន់សហភាពអឺរ៉ុប* មកពីក្រៅតំបន់សហភាពអឺរ៉ុប និងមានតម្លៃសរុបមិនលើសពី €150។ IOSS អាចប្រើប្រាស់បានតែសម្រាប់ការនាំចូលមានតម្លៃក្នុងកម្រិតនេះប៉ុណ្ណោះ។

4. សូមប្រើប្រាស់ឧបករណ៍ដឹកជញ្ជូនតាមអ៊ីនធឺណិតរបស់យើងដើម្បីធ្វើការផ្ញើទំនិញ (សូមមើលពត៌មានលម្អិតនៅលើទំព័របន្ទាប់)។ FedEx និង TNT អាចទទួលយកលេខ IOSS បានតែតាមរយៈវិធីនេះប៉ុណ្ណោះ—លោកអ្នក មិនអាចដាក់ស្នើ Air Waybill ធ្វើដោយដៃបានទេ ប្រសិនបើលោកអ្នកចង់ប្រើប្រាស់ IOSS។

5. សូមបញ្ចូលលេខ IOSS 12 ខ្ទង់របស់លោកអ្នកក្នុងកន្លែងដែលត្រឹមត្រូវ (សូមមើលពត៌មានលម្អិតនៅក្នុងទំព័របន្ទាប់)។ សូមកុំបន្ថែមអក្សរ លេខ ឬតួអក្សរផ្សេងទៀត ដូចជា “IOSS” នៅខាងដើមឲ្យសោះ។ ប្រសិនបើមានការបន្ថែមណាមួយ លេខ IOSS របស់លោកអ្នក អាចនឹងមិនស្គាល់នោះទេ។

6. ប្រសិនបើចង់ប្រើប្រាស់ IOSS សូមកុំបញ្ចូលឈ្មោះអាជីវកម្មនៅក្នុងអាសយដ្ឋានអ្នកទទួល។ ប្រសិនបើបញ្ចូល អាជ្ញាធរគយ អាចចាត់ទុកថាជាបញ្ញើទំនិញ B2B ហើយនឹងមិនខ្វល់ពីលេខ IOSS របស់លោកអ្នកទេ។



## ការបញ្ចូលលេខ IOSS របស់លោកអ្នក

នៅពេលប្រើប្រាស់ IOSS លោកអ្នកត្រូវផ្តល់លេខ IOSS នៅពេលបង្កើតការដាក់បញ្ញើ។ ពត៌មានលម្អិតអំពីវិធីធ្វើវា អាស្រ័យទៅតាមកម្មវិធីដឹកជញ្ជូនស្វ័យប្រវត្តិដែលលោកអ្នកប្រើប្រាស់។

ប្រសិនបើលោកអ្នក ប្រើប្រាស់កម្មវិធីណាមួយក្នុងចំណោមនេះ លោកអ្នកត្រូវបញ្ចូលលេខ IOSS នៅក្នុងកន្លែងដែលបានបន្លិចឡើងនៅពេលបង្កើតការដាក់បញ្ញើ។




សូមចងចាំថា បញ្ចូលតែលេខ IOSS 12 ខ្ទង់ប៉ុណ្ណោះ (ឧទាហរណ៍ “AB1324354657”)។
សូមកុំបន្ថែមពាក្យ “IOSS” នៅខាងដើម ឬបន្ថែមអ្វីផ្សេងទៀតឲ្យសោះនៅកន្លែងនេះ។

### ប្រសិនបើលោកអ្នកប្រើប្រាស់ FedEx Web Services

សូមបញ្ចូលលេខ IOSS របស់លោកអ្នកក្នុងកន្លែង TIN

### ប្រសិនបើលោកអ្នកប្រើប្រាស់ TNT ExpressConnect

សូមបញ្ចូលលេខ IOSS របស់លោកអ្នកក្នុងកន្លែង VAT

### ប្រសិនបើលោកអ្នកប្រើប្រាស់ដំណោះស្រាយបញ្ចូលគ្នា ដើម្បីបង្កើតឯកសារទិន្នន័យ EDI TNT NFF

លោកអ្នកត្រូវបញ្ចូលលេខ IOSS របស់លោកអ្នកក្នុងកន្លែង VAT

### ប្រសិនបើលោកអ្នកប្រើប្រាស់ TNT EDI Customised solution ដើម្បីដាក់បញ្ញើ

លោកអ្នក ត្រូវទំនាក់ទំនងតំណាងផ្នែកលក់របស់លោកអ្នក ដើម្បីស្នើឱ្យក្រុមបច្ចេកទេសរបស់អតិថិជនរបស់យើងទាក់ទងទៅកាន់លោកអ្នកវិញ។

### ប្រសិនបើលោកអ្នកកំពុងរួមបញ្ចូលប្រព័ន្ធផ្ទាល់ខ្លួនរបស់លោកអ្នកជាមួយឧបករណ៍ស្តង់ដាររបស់យើងណាមួយ

លោកអ្នក ប្រហែលជាត្រូវកែសម្រួលការបែងចែកពត៌មានរបស់លោកអ្នកទៅកន្លែងណាមួយដែលសមរម្យ។ ប្រសិនបើត្រូវការ សូមទំនាក់ទំនងតំណាងផ្នែកលក់របស់លោកអ្នក ដើម្បីស្នើឱ្យក្រុមបច្ចេកទេសរបស់អតិថិជនរបស់យើងទាក់ទងទៅកាន់លោកអ្នកវិញ។

### ប្រសិនបើលោកអ្នកដាក់បញ្ញើតាមរយៈកម្មវិធីដែលមិនមែនជាកម្មសិទ្ធិរបស់ FedEx ឬ TNT

លោកអ្នក គួរតែទំនាក់ទំនងទៅកាន់អ្នកផ្តល់សេវាជូនលោកអ្នក ដើម្បីឱ្យពួកគេផ្តល់ពត៌មានលម្អិតសម្រាប់កម្មវិធីដែលលោកអ្នកប្រើប្រាស់។




ⓘ ប្រសិនបើលោកអ្នកប្រើប្រាស់កម្មវិធីដឹកជញ្ជូនដែលមិនបានបង្ហាញនៅក្នុងឯកសារនេះ លោកអ្នកនឹងត្រូវផ្លាស់ប្តូរទៅប្រើកម្មវិធីដែលអនុលោម - ដូចជា FedEx Ship Manager™ នៅលើ fedex.com ឬ MyTNT2 ដើម្បីប្រើប្រាស់ IOSS បាន។

## បញ្ជីត្រួតពិនិត្យបញ្ញើ IOSS របស់លោកអ្នក

សូមប្រាកដថា លោកអ្នកអាចនិយាយថាបាទ/ចាស ចំពោះគ្រប់ចំណុចខាងក្រោម មុននឹងផ្ញើបញ្ញើរបស់លោកអ្នកតាម IOSS ។

1. តើការលក់ត្រូវបានធ្វើឡើងនៅលើគេហទំព័រអេឡិចត្រូនិករបស់លោកអ្នកឬ?

2. តើបញ្ញើទំនិញផ្ញើទៅកាន់អ្នកប្រើប្រាស់ដែលជាបុគ្គល និងមិនមែនសម្រាប់អាជីវកម្មឬ?

3. តើទំនិញត្រូវបាននាំចូលទៅសហភាពអឺរ៉ុបពីទីតាំងដែលនៅក្រៅសហភាពអឺរ៉ុបឬ?

4. តើតម្លៃសរុបនៃបញ្ញើមានតម្លៃ €150 ឬតិចជាងនេះឬ?

5. តើទំនិញអាចដឹកជញ្ជូនដោយគ្មានការបង់ពន្ធលើមុខទំនិញឬទេ?

6. តើលោកអ្នកបានបង្កើតការដាក់បញ្ញើដោយប្រើប្រាស់កម្មវិធីដឹកជញ្ជូនតាមអ៊ីនធឺណិតរបស់យើងហើយឬនៅ?

7. តើលោកអ្នកបានបន្ថែមលេខ IOSS 12 ខ្ទង់នៅក្នុងកន្លែងដែលត្រឹមត្រូវដោយគ្មានបន្ថែម អក្សរ លេខ ឬតួអក្សរផ្សេងទៀតហើយឬនៅ? ឧទាហរណ៍៖ “AB1425364758” មិនមែន “IOSS AB1425364758” ទេ

8. ប្រសិនបើអ្នកកំពុងដឹកជញ្ជូនទៅកាន់អាសយដ្ឋានសាជីវកម្ម តើលោកអ្នកអាចធានាថាអាសយដ្ឋានមិនមានរួមបញ្ចូលឈ្មោះអាជីវកម្មហើយឬនៅ?

*ប្រទេសសមាជិកសហភាពអឺរ៉ុបរួមមាន៖ អូទ្រីស បែលហ្ស៊ិក ប៊ុលហ្គារី ក្រូអាត ស៊ីពរ៍ សាធារណរដ្ឋឆែក ដាណឺម៉ាក អេស្តូនៀ ហ្វាំងឡង់ បារាំង អាល្លឺម៉ង់ ក្រិក ហុងគ្រី អៀរឡង់ អ៊ីតាលី ឡាតវីយ៉ា លីទុយអានី លុចសំបួ ម៉ាល់តា ហូឡង់ ប៉ូឡូញ ព័រទុយហ្គាល់ រូម៉ានី ស្លូវ៉ាគៀ ស្លូវេនៀ អេស្ប៉ាញ និងស៊ុយអែដ។ សូមចំណាំថា ស្របតាមកិច្ចព្រមព្រៀងរួមរបស់សហភាពអឺរ៉ុប-ចក្រភពអង់គ្លេស ភាពខាងត្បូងនៃអៀរឡង់នៅតែជាផ្នែកនៃតំបន់ VAT សហភាពអឺរ៉ុប VAT សម្រាប់ទំនិញ។ នេះមានន័យថា ការផ្លាស់ប្តូរ VAT របស់សហភាពអឺរ៉ុប ក៏អនុវត្តទៅលើទំនិញនាំមកពីកន្លែងផ្សេងទៀតទូទាំងពិភពលោក ចូលទៅកាន់ភាគខាងត្បូងនៃប្រទេសអៀរឡង់ផងដែរ។

ប្រសិនបើលោកអ្នកមានសំណួរណាមួយអំពីការប្រើប្រាស់ IOSS នៅពេលផ្ញើបញ្ញើទៅកាន់សហភាពអឺរ៉ុប រួមទាំងរបៀបក្នុងការបំពេញព័ត៌មានកម្មិតដែលទាមទារពេលបង្កើតការដាក់បញ្ញើនៅលើកម្មវិធីដឹកជញ្ជូនរបស់យើង សូមទំនាក់ទំនងទៅកាន់អ្នកគ្រប់គ្រងគណនីរបស់លោកអ្នក។ ពួកគេ នឹងអាចរៀបចំឲ្យក្រុមបច្ចេកទេសរបស់អតិថិជនរបស់យើងជួយលោកអ្នកបាន។ សម្រាប់ព័ត៌មានបន្ថែមអំពី IOSS និងការផ្លាស់ប្តូរសំខាន់ៗផ្សេងទៀតស្តីពីច្បាប់អាករលើតម្លៃបន្ថែមរបស់សហភាពអឺរ៉ុប សូមចូលទៅកាន់គេហទំព័ររបស់យើង fedex.com

